## វប្បធម៌ហារ៉ាផាន ( Harappan Culture)

ហារ៉ាផាន (Harappan) គឺជាវប្បធម៌ចំណាស់មួយក្នុងចំណោមបណ្ដាវប្បធម៌ និងអរិយធម៌ដទៃទៀតនៅលើពិភពលោក។ វប្បធម៌នេះមានទីតាំងស្ថិតនៅក្នុងតំបន់នៃអរិយធម៌ឥណ្ឌូស ដែលនៅចន្លោះ ទន្លេឥណ្ឌូស និងទន្លេ Ghaggar-Hakra (រូបលេខ១)។ វប្បធម៌មានការរីកចម្រើនយ៉ាងខ្លាំងនៅភាគខាងលិចនៃឧបទ្វីបឥណ្ឌា ដែលបច្ចុប្បន្នស្ថិតនៅចន្លោះប្រទេសប៉ាគីស្ថាន និងឥណ្ឌា។[១] ចំពោះឈ្មោះ ហារ៉ាផាន ឬ ហារ៉ាប៉ា កើតចេញឡើងនៅពេលដែលអ្នកស្រាវជ្រាវបានរកឃើញនូវតំបន់ស្ថានីយបុរាណវិទ្យានៅក្នុងតំបន់ នៃទន្លេឥណ្ឌូស នៅឆ្នាំ១៩២១។[២] ចាប់ពីឆ្នាំ ១៩៥០មក ការសិក្សាលើវិសាលភាពនៃវប្បធម៌ហារ៉ាផានមានកាន់តែច្រើន និងមានការកំណាយដើម្បីស្វែងយល់ និងរកអំពីទីក្រុងសំខាន់នៅក្នុងវប្បធម៌ហារ៉ាផានជាបន្តបន្ទាប់។[៣] តាមរយៈទិន្នន័យដែលបានបង្ហាញខាងលើ និងបានមកពីកាបូន១៤ បានបង្ហាញអំពីកាលបរិច្ឆេទនៃវប្បធម៌នេះ គឺចាប់ពី ឆ្នាំ២៦០០ ទៅឆ្នាំ ១៩០០ មុនគ.ស. និងបែងចែកជាបីសម័យកាលផ្សេងគ្នា គឺសម័យកាលមុនហារ៉ាផាន (៣៥០០ឆ្នាំទៅ២៦០០ឆ្នាំ មុនគ.ស.) សម័យហារ៉ាផាន (ឆ្នាំ ២៦០០ រហូតដល់ឆ្នាំ ១៩០០ មុនគ.ស. និងសម័យកាលក្រោយហារ៉ាផាន (ឆ្នាំ ១៩០០ ទៅ ឆ្នាំ ១៤០០ មុនគ.ស.)។[៤] តាមរយៈការស្រាវជ្រាវខាងលើចំនួនទីតាំងស្ថានីយនៃវប្បធម៌ហារ៉ាផាន កើនឡើងមានប្រមាណជាង ១០០០ទីតាំង ដែលមានកាលបរិច្ឆេទចាប់ពី ឆ្នាំ ២៦០០ រហូតដល់ឆ្នាំ ១៩០០មុនគ.ស.)។[៥] ក្នុងចំណោមនោះ មានស្ថានីយប្រមាណ៤០០ស្ថិតក្នុងទឹកដីនៃប្រទេសប៉ាគីស្ថាន និងជាង ៦១៦ ស្ថិតក្នុងប្រទេសឥណ្ឌា ។

---

[១] (PDF) Reconstructing the History of Harappan Civilization (researchgate.net)

[២] www.lkouniv.ac.in_HARAPPAN_CIVILIZATION 1.pdf (lkouniv.ac.in)

[៣] Ibid, p. 39.

[៤] Ibid, p. 40.

[៥] Ibid, p. 41.

អត្ថបទដោយ៖ អេង តុលា

ក្នុងចំណោមស្ថានីយទាំងនោះ ឌុលវីរ៉ា (Dholavira) គឺជាទីក្រុងដ៏សំខាន់ជាងគេនៅក្នុងវប្បធម៌ហារ៉ាផាន បច្ចុប្បន្នស្ថិតនៅក្នុងរដ្ឋ ហ្គូចារ៉ាត ក្នុងប្រទេសឥណ្ឌា។ តាមរយៈកំណាយបុរាណវិទ្យាបានបង្ហាញឱ្យឃើញពីការរៀបចំទីក្រុង ឌុលវីរ៉ា បានបង្ហាញថា ទីក្រុងនេះមានកំពែងដីលើកព័ទ្ធជុំវិញ មានសំណង់សាធារណៈដូចជាអណ្តូងទឹក អាងទឹក ប្រព័ន្ធបង្ហូរទឹកផ្ទះប្រជាជន និងមានផ្លូវស្របតាមអក្សបណ្តោយថ្ងៃ ទទឹងថ្ងៃមនុស្សក្នុងសម័យអរិយធម៌នេះត្រូវបានគេកត់សម្គាល់ថា មានបច្ចេកទេសខ្ពស់ ដែលមានប្រព័ន្ធជាពសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ គួរបញ្ជាក់ដែរថា មុននៃការរកឃើញឌុលវីរ៉ា ទីក្រុងទាំងនេះ គឺកប់នៅក្រោមដីជ្រៅទើបនៅឆ្នាំ ១៩៦៨ ដែលមានអ្នកស្រាវជ្រាវបានកំណាយ និងសង្គ្រោះឡើងវិញ បន្ទាប់មកអ្នកស្រាវជ្រាវបានបន្តការងារសិក្សារហូតដល់ឆ្នាំ ២០០៥។[៦] ទិន្នន័យនៃការកំណាយត្រូវបានអ្នកស្រាវជ្រាវចាត់ទុកថា ជាទីក្រុងចំណាស់ជាងគេនៅក្នុងតំបន់អាស៊ីខាងត្បូងនេះ ដែលមានអាយុកាលប្រហែលជាកកើតនៅប្រមាណ ២០០០ឆ្នាំ មុនគ.ស។[៧] ចំពោះការគោរពប្រតិបត្តិសាសនា និងអក្សរវិញ យើងពុំបានដឹងច្បាស់លាស់នោះទេ គ្រាន់តែតាមរយៈការរកត្រាដែលមានអក្សរ និងមានរូបសត្វផ្សេងៗ ដែលអ្នកស្រាវជ្រាវគិតទំនងជាអានពីស្តាំទៅឆ្វេង ដែលដូចនឹងភាសាក្នុងអម្បូរ ឥណ្ឌូ-អឺរ៉ុប និងឥណ្ឌាខាងត្បូង (រូបលេខ២-៥)។[៨]

មនុស្សក្នុងអរិយធម៌នេះ មានជំនាញក្នុងការផលិតវត្ថុសិល្បៈ តាមទម្រង់ផ្សេងៗដែលបានរកឃើញពីកន្លែងជាច្រើននៃអរិយធម៌នេះរួមមានរូបចម្លាក់ត្រា គ្រឿងស្មូនដី គ្រឿងអលង្ការ រូបចម្លាក់ដី អំពីថ្ម លោហៈធាតុ និងអំពីដីឥដ្ឋជាដើម។

សរុបមកវប្បធម៌នេះ មានការរីកចម្រើនចន្លោះ ឆ្នាំ ២៦០០ មុនគ.ស. រហូតដល់ឆ្នាំ ១៩០០មុនគ.ស. និងនៅប្រហែលឆ្នាំ១៧០០មុនគ.ស. ទីក្រុងនៃវប្បធម៌នេះ ត្រូវបានគេ

[៦] https://whc.unesco.org/en/list/1645/

[៧] Brisset Isabelle 2014, p. 17

[៨] https://www.khanacademy.org:Indus River Valley civilization

អត្ថបទដោយ៖ អេង តុលា

បោះបង់ចោល[៩]គឺប្រហែល មកពីកត្តាជាច្រើនដែលធ្វើឲ្យវប្បធម៌មួយនេះធ្លាក់ចុះ រួមជាមួយនឹងតំបន់អរិយធម៌ឥណ្ឌូស ពោលមានដូចជាការបញ្ចប់ពាណិជ្ជកម្មជាមួយមេសូប៉ូតាមី និងអេហ្ស៊ីប កត្តាសង្គ្រាម និងជាពិសេសកត្តាធម្មជាតិដែលទឹកទន្លេឥណ្ឌូស និងទន្លេ Ghaggar-Hakra ស្ងួត ដែលធ្វើឲ្យខ្វះប្រភពទឹកក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។[១០]




រូបលេខ១៖ ផែនទីនៃវប្បធម៌ហារ៉ាផាន

ប្រភព៖ https://www.khanacademy.org

[៩] https://www.bbc.co.uk:

What happened to the Indus civilisation?

[១០] https://www.bbc.co.uk:

What happened to the Indus civilisation?

អត្ថបទដោយ៖ អេង តុលា



រូបលេខ២ និង ៣៖ សំណង់បុរាណក្នុងក្រុង dholavira

ប្រភព៖ https://whc.unesco.org និង https://www.tripiwiki.com/



អត្ថបទដោយ៖ អេង តុលា




រូបលេខ៤និង ៥៖ គ្រោងឆ្អឹងរកឃើញក្នុងតំបន់នៃវប្បធម៌ហារ៉ាផាន

ប្រភព៖ [www.harappa.com](http://www.harappa.com)



# ឯកសារយោង

(PDF) Reconstructing the History of Harappan Civilization (researchgate.net)

www.lkouniv.ac.in_HARAPPAN_CIVILIZATION 1.pdf (lkouniv.ac.in)

https://www.bbc.co.uk:
What happened to the Indus civilization?

Brisset Isabelle

**2014** La spécialisation du travail artisanal dans la civilisation de l’Indus.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា